មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប
# វិសោធនកម្មលើកទី១០ លើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២២

## សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ត្រូវបានសភាធម្មនុញ្ញអនុម័តជាផ្លូវការក្នុងកិច្ចប្រជុំពេញអង្គលើកទីពីរនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលប្រែក្លាយប្រទេសកម្ពុជាទៅជារដ្ឋរាជានិយមអាស្រ័យធម្មនុញ្ញ។ រយៈពេលពីរបីថ្ងៃបន្ទាប់មកព្រះមហាក្សត្រឡាយព្រះហត្ថលេខាប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ចាប់តាំងពីថ្ងៃនោះមក មានការប្រារព្ធទិវារដ្ឋធម្មនុញ្ញនៅថ្ងៃនេះជារៀងរាល់ឆ្នាំតរៀងមក។ រដ្ឋធម្មនុញ្ញត្រូវបានធ្វើវិសោធនកម្មជាច្រើនលើកមកហើយ។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២[1] ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តលើសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញថ្មីលើមាត្រាចំនួនប្រាំបីនៃច្បាប់កំពូលរបស់កម្ពុជា។[2] នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២[3] ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចទទួលស្គាល់ធម្មនុញ្ញភាព ហើយវិសោធនកម្មថ្មីទាំងនេះត្រូវបានរដ្ឋសភាអនុម័តនៅ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២២ និងព្រឹទ្ធសភាបានអនុម័តនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២។[4] នេះ គឺជាលើកទី១០ហើយដែលមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។




*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*
*រូបថត: ក្រុមប្រឹក្សាធម្មនុញ្ញ*

ដើម្បីប្រារព្ធទិវារដ្ឋធម្មនុញ្ញលើកទី២៩ នៅឆ្នាំនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ចេញផ្សាយកំណត់ត្រាដែលវិភាគសង្ខេបអំពីវិសោធនកម្មរដ្ឋធម្មនុញ្ញចុងក្រោយបង្អស់នេះ។ នៅផ្នែកដំបូងនៃកំណត់

---

[1] ម៉ិច ដារ៉ា «រដ្ឋាភិបាលជំរុញឱ្យពន្លឿនធ្វើសោធនកម្មរដ្ឋធម្មនូញ្ញ ដោយផ្តល់ការពន្យល់តិចតួច (វីអូឌី ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២)។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រួតពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជា (ក.ប.ធ ខែតុលា ឆ្នាំ២០១៥)។

[3] ហង្ស ពណ្ណរាយ «ត្រឹមត្រូវតាមច្បាប់: ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជាបានចេញសេចក្តីសម្រេចថាសេចក្តីស្នើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រឹមត្រូវតាមច្បាប់» សារព័ត៌មាន *ខ្មែរថាមស៍* ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២)។

[4] តន ចាន់វិទ្ធារ៉ា «ព្រះមហាក្សត្រ នរោត្តម សីហមុនី ឡាយព្រះហស្ថលេខាលើវិសោធនកម្មរដ្ឋធម្មនុញ្ញឱ្យក្លាយជាច្បាប់» (Cambodianess ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២២)។

ត្រាសង្ខេបនេះពន្យល់អំពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ហើយបន្ទាប់មកលើកឡើងអំពីកង្វល់សំខាន់ៗទាក់ទងនឹងការកែប្រែលើមាត្រាមួយចំនួនក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានដែលលើកឡើងនូវអនុសាសន៍មួយចំនួនជូនដល់រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល»)។

កំណត់ត្រាសង្ខេបនេះតាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## ១. វិសោធនកម្មរដ្ឋធម្មនុញ្ញនៅខែសីហា ឆ្នាំ២០២២

វិសោធនកម្មរដ្ឋធម្មនុញ្ញនៅខែសីហា ឆ្នាំ២០២២ កែសម្រួលមាត្រាចំនួន ៨ រួមមាន មាត្រា ១៩ មាត្រា ៨៩ មាត្រា ៩៨ មាត្រា ១០២ មាត្រា ១១៩ និងមាត្រា ១២៥ ព្រមទាំងមាត្រា ៣ និងមាត្រា ៤ នៃច្បាប់ធម្មនុញ្ញបន្ថែម។[5] មាត្រាទាំងនេះពាក់ព័ន្ធសំខាន់ទៅនឹងការតែងតាំងនាយករដ្ឋមន្ត្រី និងធានានូវដំណើរការជាប្រក្រតីនៃស្ថាប័ននីតិប្បញ្ញត្តិ។ តារាងខាងក្រោមប្រៀបធៀបមាត្រាមុន និងវិសោធនកម្មដែលបានអនុម័តរួចហើយ (បញ្ជាក់ក្នុងពណ៌ក្រហម) និងពន្យល់អំពីលក្ខខណ្ឌចាំបាច់នៃវិសោធនកម្មនេះ។

- **មាត្រា១៩ នៃរដ្ឋធម្មនុញ្ញ**

| សំណៅដើម | កំណែថ្មី[6] |
|---|---|
| ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី។ | ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី(ពីរ)។ |

សំណើវិសោធនកម្មមាត្រានេះធ្វើឡើងយោងទៅលើមាត្រា ១១៩ ដែលត្រូវបានធ្វើវិសោធនកម្មដែរ។

- **មាត្រា ៨៩ នៃរដ្ឋធម្មនុញ្ញ**

| សំណៅដើម | កំណែថ្មី |
|---|---|
| តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញ**ឥស្សរជនជាន់ខ្ពស់ណាមួយ**មកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។ | តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញ សមាជិករាជរដ្ឋាភិបាលមួយរូប ឬច្រើនរូប អមដោយឥស្សរជនជាអ្នក |

[5] ច្បាប់ធម្មនុញ្ញបន្ថែមត្រូវបានប្រកាសនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ក្នុងគោលបំណងធានានូវដំណើរការជាប្រក្រតីភាពនៃស្ថាប័នជាតិដោយគោរពនូវគោលការណ៍មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ សូមមើលគេហទំព័រ ក.ប.ធ។

[6] សេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២។

| | |
|---|---|
| | ជំនាញក្នុងវិស័យណាមួយមកបំភ្លឺរដ្ឋសភាអំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។ |

ទោះបីជាកំណែចាស់នៃមាត្រា៨៩ ចែងអនុញ្ញាតឱ្យរដ្ឋសភាអញ្ជើញ «*ឥស្សរជន*» ដើម្បីពិភាក្សាអំពីបញ្ហាសំខាន់ក្តី ក៏មាត្រាដែលបានធ្វើវិសោធនកម្មនេះអនុញ្ញាតឱ្យរដ្ឋសភាអញ្ជើញ «*សមាជិករាជរដ្ឋាភិបាលមួយរូប ឬច្រើនរូប*» ព្រមទាំងអ្នកជំនាញដើម្បីពិភាក្សាអំពីបញ្ហាសំខាន់។ រដ្ឋាភិបាលបានបញ្ជាក់ថា ការកែប្រែមាត្រានេះដោយសារពាក្យសព្ទ «*ឥស្សរជន*» មានន័យមិនច្បាស់លាស់ និងថាគួរតែសំដៅទៅលើសមាជិកនៃស្ថាប័ននីតិប្រតិបត្តិ ឬរដ្ឋាភិបាល ដែលជាការបញ្ជាក់ច្បាស់ពីទំនួលខុសត្រូវរបស់ពួកគេនៅចំពោះមុខរដ្ឋសភា។[7]

- **មាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញ**

| សំណៅដើម | កំណែថ្មី |
|---|---|
| រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួន**សាបសិបនាក់**នៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ | រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីមុខតំណែងនេះមានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ |

[7] អ៊ុច សុនី «វិសោធនកម្មរដ្ឋធម្មនុញ្ញបំពេញគម្លាតក្នុងអន្តរកាលនៃការផ្លាស់ប្តូរអំណាច» រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (វីអូឌី ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២)។

ការកែប្រែចំនួនពីរចំណុចត្រូវបានធ្វើឡើងទៅលើមាត្រា ៩៨៖ ទីមួយ បន្ថែមនូវដំណើរការ របស់ រដ្ឋាភិបាលជាបណ្តោះអាសន្នក្នុងពេលដែលរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយការអនុម័តញត្តិបន្ទោស។ ទីពីរ ផ្លាស់ប្តូរចំនួនសមាជិករដ្ឋសភាដែលត្រូវការយ៉ាងតិច ដើម្បីស្នើញត្តិបន្ទោសប្រឆាំងរដ្ឋាភិបាល។ មុនការធ្វើវិសោធនកម្ម ញត្តិបន្ទោសនេះអាចស្នើឡើងដោយសមាជិករដ្ឋសភាយ៉ាងតិច ៣០រូប។ មាត្រា ៩៨ ថ្មី នេះតម្រូវឱ្យមានសមាជិកចំនួនមួយភាគបីនៃសមាជិករដ្ឋសភាដើម្បីស្នើសុំទម្លាក់រាជរដ្ឋាភិបាល។ ក្នុងពេលបច្ចុប្បន្ន រដ្ឋសភាមានអាសនៈចំនួន១២៥ ដូចនេះត្រូវការសមាជិករដ្ឋសភាចំនួន ៤១រូប ដើម្បីលើកឡើងនូវញត្តិបន្ទោសក្នុងការដករដ្ឋាភិបាលពីតំណែង។ ការធ្វើវិសោធនកម្មលើកនេះធ្វើឱ្យកើនឡើងចំនួនសមាជិកក្នុងការរៀបចំសំណើប្រសិនបើប្រៀបធៀបទៅនឹងចំនួនសមាជិកពីមុនដែលតម្រូវឱ្យមានត្រឹមតែ ៣០រូប ដូច្នេះ ការអនុម័តញត្តិបន្ទោសរដ្ឋាភិបាលមានភាពលំបាកជាងមុន។ បន្ថែមពីនេះ ចំនួននេះនឹងប្រែប្រួលទៅតាមការប្រែប្រួលចំនួនអាសនៈសរុបរបស់រដ្ឋសភា។ ប្រសិនបើអាសនៈត្រូវបានបន្ថែមទៀតទៅក្នុងរដ្ឋសភា ដូចដែលបានកើតឡើងក្នុងឆ្នាំ២០១៨ នៅពេលអាសនៈរដ្ឋសភាចំនួនពីរត្រូវបានបន្ថែម ដែលធ្វើឱ្យចំនួនអាសនៈសរុបមានការកើនឡើងពី១២៣ ទៅ១២៥[8] ចំនួនសមាជិករដ្ឋសភាដែលត្រូវការដើម្បីស្នើញត្តិបន្ទោសរដ្ឋាភិបាលនឹងកើនឡើងផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានបកស្រាយថា ការស្នើសុំកែប្រែលើកដំបូងនេះធ្វើឡើងក្នុងគោលបំណងធានាឱ្យមានច្បាប់ដើម្បីការពាររដ្ឋាភិបាលបណ្តោះអាសន្ន ក្នុងអំឡុងពេលធ្វើការផ្លាស់ប្តូរអំណាចទៅឱ្យរដ្ឋាភិបាលថ្មី។ ការកែប្រែទីពីរ គឺដើម្បីធានាថារាជរដ្ឋាភិបាលអាចប្រតិបត្តិការដោយគ្មានការរាំងស្ទះ ហើយការសម្តែងការមិនពេញចិត្ត គឺធ្វើឡើងចំពោះតែ"បញ្ហាសំខាន់"ប៉ុណ្ណោះ។[9]

- **មាត្រា ១០២ នៃរដ្ឋធម្មនុញ្ញ**

| សំណៅដើម | កំណែថ្មី |
|---|---|
| នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសម្រេច | នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។<br>ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាល |

[8] មុំ សុផុន, "អាសនៈចំនួនពីរទៀតត្រូវបានបន្ថែមក្នុងរដ្ឋសភាជាតិ" (ខ្មែរថាមស៍, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨)

[9] អ៊ុច សុនី «វិសោធនកម្មរដ្ឋធម្មនុញ្ញបំពេញគម្លាតក្នុងអន្តរកាលនៃការផ្លាស់ប្តូរអំណាច» រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (អ្វែឌី ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២២)។

| | |
|---|---|
| ដោយមតិយល់ព្រមពីភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br><br>ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។<br><br>បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវតែបន្តទៅមុខជាស្វ័យប្រវត្តិ។ | របស់ព្រឹទ្ធសភាត្រូវសម្រេចដោយមតិយល់ព្រមពីភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។<br><br>ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត។ ប៉ុន្តែ ការសម្រេចបញ្ចប់កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ព្រឹទ្ធសភាត្រូវសម្រេចរួមគ្នាជាមួយរដ្ឋសភាក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភា វៀរលែងតែការអនុវត្តមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញ។<br><br>បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវតែបន្តទៅមុខជាស្វ័យប្រវត្តិ។ |

ច្បាប់មុនរបស់រដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិទៅកាន់ព្រឹទ្ធសភា និងរដ្ឋសភាសម្រេចបញ្ចប់ការដាក់ប្រទេសក្នុងភាពអាសន្ននៅក្នុងឃ្លាចំនួនពីរផ្សេងគ្នា៖ មាត្រា ១០២ សម្រាប់ព្រឹទ្ធសភា និងមាត្រា ៨៦ សម្រាប់រដ្ឋសភា។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញថ្មីទៅលើមាត្រា ១០២ តម្រូវឱ្យព្រឹទ្ធសភា និងរដ្ឋសភាសម្រេចរួមគ្នានៅក្នុងការបញ្ចប់ការដាក់ប្រទេសក្នុងភាពអាសន្ន។ រាជរដ្ឋាភិបាលកម្ពុជាបានពន្យល់ថា ហេតុផលនៃការធ្វើវិសោធនកម្មនេះ គឺតម្រូវឱ្យស្ថាប័នសភាទាំងពីរធ្វើការសម្រេចចិត្តរួមគ្នាមួយដើម្បីបញ្ចៀសការសម្រេចផ្ទុយគ្នា។[10] ប៉ុន្តែមាត្រា ១០២ ថ្មី បានចែងថារដ្ឋសភា និងព្រឹទ្ធសភាត្រូវសម្រេចរួមគ្នា វៀរលែងតែការអនុវត្តមាត្រា ៨៦ នៃរដ្ឋធម្មនុញ្ញ ដែលមានន័យថាប្រសិនបើរដ្ឋសភាប្រើអំណាចដើម្បីបញ្ចប់ការដាក់ប្រទេសក្នុងភាពអាសន្នក្រោមមាត្រា ៨៦ ការសម្រេចរួមគ្នាជាមួយព្រឹទ្ធសភានឹងមិនត្រូវបានតម្រូវឡើយ។

[10] ដូចខាងលើ

- មាត្រា ១១៩ នៃរដ្ឋធម្មនុញ្ញ

| សំណេរដើម | កំណែថ្មី |
|---|---|
| តាមសេចក្ដីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរដ្ឋាភិបាល។<br><br>វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងតំណាងនៅក្នុងរដ្ឋសភា ដែលផ្ដូងផ្ដងឱ្យកាន់តំណែងផ្សេងៗនៅក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។<br>កាលបើរដ្ឋសភាបានបោះឆ្នោតសេចក្ដីទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦។ | តាមសេចក្ដីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្ដីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះត្រូវចម្លងជូនប្រធានរដ្ឋសភា។<br>វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងដែលត្រូវបានជ្រើសរើសពីគណបក្សដែលអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។<br><br>វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្ដូវផ្ដងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។<br><br>កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។<br><br>នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។ |

មាត្រា១១៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែមួយចំនួន និងបំពេញបន្ថែម។ ទីមួយ ប្រធានរដ្ឋសភា និងអនុប្រធានរដ្ឋសភាលែងមានអំណាចក្នុងការតែងតាំងតំណែងនាយករដ្ឋមន្ត្រី ដោយវិសោធនកម្មមាត្រា ១១៩ ផ្តល់អំណាចនេះទៅ«គណបក្សដែលមានអាសនៈច្រើនបំផុតក្នុងរដ្ឋសភា»។ គណបក្សដែលមានអាសនៈច្រើនបំផុតគ្រាន់តែធ្វើសេចក្តីស្នើចម្លងទៅរដ្ឋសភាតែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីបំណងក្នុងការផ្តល់ករណីកិច្ចនៃការជ្រើសរើសនាយករដ្ឋមន្ត្រី និងការបង្កើតគណៈរដ្ឋមន្ត្រីទៅកាន់គណបក្សដែលមានអាសនៈច្រើនបំផុតក្រោមហេតុផលដែលគណបក្សនោះ «ត្រូវបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ»។[11]
ទីពីរ វិសោធនកម្មនៃមាត្រានេះតម្រូវឱ្យនាយករដ្ឋមន្ត្រីជាអ្នកតំណាងរាស្ត្រ និងមានសញ្ជាតិខ្មែរតែមួយគត់។ សេចក្តីតម្រូវនេះ មានមូលដ្ឋានពីវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី៩ ដែលចូលជាធរមាននៅខែវិច្ឆិកា ឆ្នាំ២០២១ ដែលហាមប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានសញ្ជាតិពីរ។.[12]
ជាចុងបញ្ចប់ ហើយក៏ដូចទៅនឹងវិសោធនកម្មមាត្រា៩៨ នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌមួយត្រូវបានបន្ថែមស្តីពីការផ្ទេរអំណាចរវាងរដ្ឋាភិបាលដែលត្រូវចេញពីតំណែង និងរដ្ឋាភិបាលដែលត្រូវចូលកាន់តំណែង នៅចប់នីតិកាលនីមួយៗ ក្នុងបំណងធានាប្រសិទ្ធិភាពអភិបាលកិច្ចប្រចាំថ្ងៃអំឡុងពេលផ្ទេរអំណាចទៅរដ្ឋាភិបាលថ្មី។

- **មាត្រា១២៥ នៃរដ្ឋធម្មនុញ្ញ**

| សំណៅដើម | កំណែថ្មី |
| --- | --- |
| បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទីជាបណ្តោះអាសន្ន។ | ក្នុងករណីដែលនាយករដ្ឋមន្ត្រីអវត្តមានមួយកាលមួយគ្រា នាយករដ្ឋមន្ត្រីត្រូវចាត់តាំងឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទី ដើម្បីទទួលភារកិច្ចដឹកនាំគណៈរដ្ឋមន្ត្រីជំនួសជាបណ្តោះអាសន្ន។<br>បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុជាអាទិ៍មកពីការទទួលអនិច្ចកម្ម ឬការលាលែងពីមុខតំណែង គណៈរដ្ឋមន្ត្រីថ្មីមួយត្រូវតែងតាំងជាបន្ទាន់ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ ប្រធានរដ្ឋសភាត្រូវកោះប្រជុំរដ្ឋសភាជាបន្ទាន់ និងត្រូវធ្វើចំណាត់ការចាំបាច់ដទៃទៀតដោយរួសរាន់ ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសំណើពីគណបក្សដែលមានអាសនៈច្រើនជាង |

[11] ដូចខាងលើ
[12] ព្រះរាជក្រមលេខ នស/រកម/១១២១/០១៦ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២១

| | |
|---|---|
| | គេក្នុងរដ្ឋសភា។ ក្នុងករណីតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរ ដោយហេតុមកពីការទទួលអនិច្ចកម្ម គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រីដែលទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីស្តីទី មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានគណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។<br>ការលាលែងពីមុខតំណែងរបស់នាយករដ្ឋមន្ត្រីត្រូវធ្វើឡើងតាមលិខិតលាលែងពីមុខតំណែងដែលត្រូវធ្វើថ្វាយព្រះមហាក្សត្រ និងចម្លងជូនប្រធានរដ្ឋសភា។ ក្នុងករណីនេះ គណៈរដ្ឋមន្ត្រីដែលត្រូវចេញពីតំណែង ត្រូវបន្តដឹកនាំការងាររបស់រាជរដ្ឋាភិបាលរហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់តំណែង។ |

មាត្រា១២៥ ទំនងជាមាត្រាដែលត្រូវបានកែប្រែយ៉ាងសំខាន់ជាងគេបំផុត។ នីតិវិធីលម្អិតត្រូវបានបំពេញបន្ថែមក្នុងករណីអវត្តមានជាស្ថាពរនៃតំណែងនាយករដ្ឋមន្ត្រី (ឧ. មរណភាព ឬការលាលែងចេញពីតំណែងរបស់នាយករដ្ឋមន្ត្រី)។ មាត្រា១២៥ តម្រូវឱ្យប្រធានរដ្ឋសភាចាត់វិធានការចាំបាច់ក្នុងរយៈពេលប្រាំពីរថ្ងៃ ក្រោយទទួលបានសេចក្តីស្នើតែងតាំងនាយករដ្ឋមន្ត្រីថ្មី ពីគណបក្សដែលមានអាសនៈច្រើនបំផុតក្នុងរដ្ឋសភា។ បន្ថែមពីនេះ ក្នុងករណីដែលតំណែងនាយករដ្ឋមន្ត្រីទំនេរជាបណ្តោះអាសន្ន មាត្រា ១២៥ ផ្តល់អំណាចដល់នាយករដ្ឋមន្ត្រី ក្នុងការចាត់តាំងដោយផ្ទាល់នូវឧបនាយករដ្ឋមន្ត្រីមួយរូប ឱ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីអំឡុងពេលអវត្តមាន ដែលពីដើមឡើយអំណាចក្នុងការចាត់តាំងនេះជារបស់ប្រធាន និងអនុប្រធានរដ្ឋសភា។ មាត្រាថ្មីនេះបញ្ជាក់ពីករណីទំនេរជាស្ថាពរ(ដោយមូលហេតុមរណភាព ឬលាលែងពីតំណែង)នៃតំណែងនាយករដ្ឋមន្ត្រី។ ឧបនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំង នឹងដឹកនាំរដ្ឋាភិបាលរហូតដល់គណៈរដ្ឋមន្ត្រីថ្មីចូលកាន់មុខតំណែង។ ជាចុងបញ្ចប់ មាត្រានេះចែងពីនីតិវិធីសម្រាប់ការលាលែងចេញពីតំណែងរបស់នាយករដ្ឋមន្ត្រី ដែលរដ្ឋធម្មនុញ្ញពីមុនពុំដែលបានចែងឡើយ។ ដោយហេតុនេះ គណៈរដ្ឋមន្ត្រីមានបន្ទុកដឹកនាំរដ្ឋាភិបាល រហូតនាយករដ្ឋមន្ត្រីថ្មីត្រូវបានជ្រើសតាំង ហើយគណៈរដ្ឋមន្ត្រីថ្មីត្រូវបានបង្កើត។

រាជរដ្ឋាភិបាលកម្ពុជា អះអាងពីមូលហេតុនៃវិសោធនកម្មនេះ ដោយភាពចាំបាច់ក្នុងការបញ្ជាក់ពីគ្រប់សេណារីយ៉ូទាំងអស់ដែលអាចកើតឡើង និងចំណាត់ការចាំបាច់អំឡុងពេលអវត្តមានជាបណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍នៃនាយករដ្ឋមន្ត្រី ដើម្បីបង្ការអស្ថិរភាពនៅប្រមុខរដ្ឋាភិបាលអវត្តមាន។[13]

- **មាត្រា៣ នៃច្បាប់ធម្មនុញ្ញបន្ថែម**

| សំណៅដើម | កំណែថ្មី |
|---|---|
| ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា៨២ និងមាត្រា១១៩ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ | ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ ថ្មី (មួយ) និងមាត្រា១១៩ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ មិនអាចសម្រេចបាន រដ្ឋសភា តាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភាអាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នានឹងការផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល។ |

ការកែប្រែនេះហាក់ដូចជាធ្វើបច្ចុប្បន្នភាពតែមាត្រារដ្ឋធម្មនុញ្ញដែលយោងក្នុងមាត្រា ៣ នៃច្បាប់ធម្មនុញ្ញបន្ថែមប៉ុណ្ណោះ។

- **មាត្រា ៤ នៃច្បាប់ធម្មនុញ្ញបន្ថែម**

| សំណៅដើម | កំណែថ្មី |
|---|---|
| ការរៀបចំបញ្ជីរាយនាមសមាសភាពដើម្បីបោះឆ្នោតជ្រើសតាំង និងផ្ដល់សេចក្ដីទុកចិត្តត្រូវអនុវត្តដូចតទៅ៖<br>- បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណៈ | ការរៀបចំបញ្ជីរាយនាមសមាសភាព ដើម្បីបោះឆ្នោតជ្រើសតាំង និងផ្ដល់សេចក្ដីទុកចិត្តត្រូវអនុវត្តដូចតទៅ៖<br>- បញ្ជីរាយនាមសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ត្រូវរៀបចំនិងស្នើដោយគណៈបក្ស |

[13] អ៊ូច សូនី «វិសោធនកម្មរដ្ឋធម្មនុញ្ញបំពេញគម្លាតក្នុងអន្តរកាលនៃការផ្លាស់ប្ដូរអំណាច» រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (អ៊ែឌី ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២)។

| | |
|---|---|
| បក្សនយោបាយដែលព្រមព្រៀងគ្នាដើម្បីបង្កើតរាជរដ្ឋាភិបាលចម្រុះ ហើយត្រូវផ្ញើជូនព្រឹទ្ធិសមាជិករដ្ឋសភា។ ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់ ។<br>- តាមសេចក្តីស្នើពីគណបក្សនយោបាយដែលមានចំនួនអាសនៈច្រើនជាងគេ នៅក្នុងរដ្ឋសភាតាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីពីក្នុងចំណោមតំណាងរាស្ត្រនៃគណៈបក្សនយោបាយដែលានចំនួនអាស នៈច្រើនជាងគេនៅក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា។<br>- ព្រឹទ្ធសមាជិករដ្ឋសភាត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ | នយោបាយ**ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា** ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា។ **ប្រធានរដ្ឋសភា ត្រូវជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។**<br>- តាមសេចក្តីស្នើពីគណៈបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រី ឱ្យបង្កើតរាជរដ្ឋាភិបាល។ **វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះ ត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់** និងដែលត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជីរាយនាមសមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធិសមាជិករដ្ឋសភា។<br>- ព្រឹទ្ធិសមាជិករដ្ឋសភាត្រូវរៀបចំជាបន្ទាន់ និងដោយឥតបង្អង់នូវបញ្ជីរាយនាមជាកញ្ចប់មួយដែលរួមមានសមាសភាពប្រធាន និងអនុប្រធាននៃរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងនាយករដ្ឋមន្ត្រីដែលត្រូវបានចាត់ តាំងដោយព្រះមហាក្សត្រនិងសមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត។ **ព្រឹទ្ធសមាជិករដ្ឋសភាត្រូវដឹកនាំប្រជុំសភា ដើម្បីបោះឆ្នោតអនុម័តបញ្ជីនេះជាបន្ទាន់។**<br>- **ព្រឹទ្ធសមាជិករដ្ឋសភាត្រូវបានជ្រើសរើសដោយកំណត់យកសមាជិករដ្ឋសភា ដែលមាន** |

| | |
|---|---|
| | អាយុច្រើនជាងគេ ក្នុងចំណោមសមាជិករដ្ឋសភាទាំងអស់។ ក្នុងករណីដែលព្រឹទ្ធសមាជិករដ្ឋសភារូបនេះមិនអាចអនុវត្តមុខងាររបស់ខ្លួនបាន មុខតំណែងព្រឹទ្ធសមាជិករដ្ឋសភាត្រូវប្រគល់ទៅសមាជិករដ្ឋសភាដទៃទៀតដែលមានអាយុច្រើនក្នុងលំដាប់បន្តបន្ទាប់។ |

ការផ្លាស់ប្តូរដែលបានធ្វើឡើងនៅក្នុងមាត្រានេះ បានផ្តល់ព័ត៌មានយ៉ាងលម្អិតបន្ថែមលើការរៀបរាប់អំពីបញ្ជីរាយនាមសមាសភាពសម្រាប់តំណែងប្រធាន និងអនុប្រធានរដ្ឋសភា និងការបោះឆ្នោត និងការអនុម័តបញ្ជីរាយនាមសមាសសភាព។ មាត្រា ៤ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែមក៏តម្រូវឱ្យប្រធានរដ្ឋសភាមានសញ្ជាតិខ្មែរតែមួយ។ ការកែប្រែនេះឆ្លុះបញ្ចាំងពីវិសោធនកម្មលើកទី៩ នៃរដ្ឋធម្មនុញ្ញដែលបានប្រកាសឱ្យប្រើក្នុងខែវិច្ឆិកាឆ្នាំ២០២១ ដោយហាមប្រាមប្រធានរដ្ឋសភា និងព្រឹទ្ធសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញដោយមិនអាចមានសញ្ជាតិពីរ។

ជាងនេះទៅទៀត មាត្រាថ្មីក៏បានកំណត់លទ្ធភាពនៃការស្នើសុំបញ្ជីឈ្មោះប្រធានរដ្ឋសភា និងអនុប្រធានគណបក្សនយោបាយដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ខណៈដែលមាត្រាមុនបានអនុញ្ញាតឱ្យសមាជិកនៃគណបក្សនយោបាយផ្សេងទៀតអាចស្នើឈ្មោះប្រសិនបើពួកគេយល់ព្រមបង្កើតរដ្ឋាភិបាលចម្រុះ។ រាជរដ្ឋាភិបាលបានធ្វើអត្ថាធិប្បាយថាការកែប្រែចុងក្រោយនេះ ត្រូវបានធ្វើឡើងដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នាជាមួយនឹងវិសោធនកម្មផ្សេងទៀត ប៉ុន្តែមិនបានបដិសេធលទ្ធភាពនៃការមានរដ្ឋាភិបាលចម្រុះនាពេលអនាគតនោះទេ។.[14]

## ២. កង្វល់សំខាន់ៗដែលផ្តោតលើវិសោធនកម្មថ្មីនេះ

រាជរដ្ឋាភិបាលកម្ពុជាបានអះអាងចំពោះវិសោធនកម្មថ្មីនេះថាមានភាពចាំបាច់ ដើម្បីធានាបាននូវដំណើរការត្រឹមត្រូវរបស់រដ្ឋាភិបាល និងបំពេញចន្លោះប្រហោងក្នុងការផ្លាស់ប្តូរអំណាចរវាងអាណត្តិរដ្ឋាភិបាល។[15] ទោះយ៉ាងណាក៏ដោយ ដោយសារស្ថានភាពបច្ចុប្បន្នរបស់កម្ពុជាជារដ្ឋឯកបក្ស និងការគំរាមកំហែងបន្តបន្ទាប់លើគណបក្សប្រឆាំង ក្តីបារម្ភបានកើតឡើងទាក់ទងនឹងរបៀបវារៈនយោបាយរបស់រដ្ឋាភិបាលកម្ពុជា អាចនៅពីក្រោយការកែប្រែរដ្ឋធម្មនុញ្ញទាំងនេះ។

វិសោធនកម្មនេះ ត្រូវបានគេរិះគន់ថា ជាការប៉ុនប៉ងរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការក្តាប់អំណាចរបស់ខ្លួនបន្ថែមទៀត ដោយកាត់បន្ថយអភ័យឯកសិទ្ធិមួយចំនួនរបស់រដ្ឋសភា - ស្ថាប័នសភាតំណាងឱ្យប្រជា

---

[14] ដូចខាងលើ

[15] ដូចខាងលើ

ពលរដ្ឋ ហើយជំនួសមកវិញការបង្កើនការប្រមូលផ្តុំអំណាចរបស់គណបក្សកាន់អំណាច។[16] ដូចដែលបានបញ្ជាក់រួចមកហើយ ការតែងតាំងនាយករដ្ឋមន្ត្រីមិនមែនជាអភ័យឯកសិទ្ធិរបស់ប្រធាន និងអនុប្រធានរដ្ឋសភាទៀតទេ ប៉ុន្តែជា "គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា" យោងតាមមាត្រា ១១៩ ថ្មី។ ដូចគ្នានេះដែរ លទ្ធភាពនៃការស្នើសុំបេក្ខជនសម្រាប់តំណែងប្រធាន និងអនុប្រធានរដ្ឋសភាឥឡូវនេះត្រូវបានបម្រុងទុកសម្រាប់ "គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា" យោងតាមមាត្រាទី ៤ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម នៅពេលដែលមាត្រាចាស់បានអនុញ្ញាតឱ្យគណបក្សផ្សេងទៀតដែលបានយល់ព្រមបង្កើតរដ្ឋាភិបាលចម្រុះ ដើម្បីស្នើសមាសសភាព។ ការកើនឡើងចំនួននៃសមាជិករដ្ឋសភាដែលតម្រូវឱ្យស្នើឱ្យមាន(ការតតាំង) ឬញត្តិបន្ទោស ដែលជាឧបករណ៍សំខាន់នៃការត្រួតពិនិត្យរបស់សភាលើផ្នែកប្រតិបត្តិ ពង្រឹងជំហររបស់រដ្ឋាភិបាលបន្ថែមទៀត។ មាត្រា ៩៨ ដែលត្រូវបានកែសម្រួលធ្វើឱ្យមានការលំបាកជាងមុនសម្រាប់សមាជិករដ្ឋសភាដែលមិនយល់ព្រម ចំពោះសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបណ្តេញចេញ និងជំនួស ដែលធ្វើឱ្យការត្រួតពិនិត្យ និងមានតុល្យភាព ដែលចាំបាច់ដើម្បីការពារការរំលោភបំពានអំណាច។

មាត្រា ១២៥ ថ្មីនេះ ត្រូវបានគេយល់ឃើញថា ច្បាប់នេះកាន់តែធ្វើឱ្យអំណាចរបស់រដ្ឋសភាចុះខ្សោយបន្ថែមទៀត ដែលបង្ហាញពីការអនុគ្រោះដល់គណបក្សកាន់អំណាច ព្រោះឥឡូវនេះ នាយករដ្ឋមន្ត្រីអាចតែងតាំងឧបនាយករដ្ឋមន្ត្រីដោយផ្ទាល់មួយរូប ដើម្បីកាន់តំណែងក្នុងករណីអវត្តមានបណ្តោះអាសន្ន ដែលគួរជាបុព្វសិទ្ធិរបស់រដ្ឋសភា។ ការផ្លាស់ប្តូរនេះក៏ត្រូវបានរិះគន់ថាអាចជាមធ្យោបាយឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្រួលការផ្ទេរអំណាចឱ្យកូនប្រុសរបស់លោកគឺលោក ហ៊ុន ម៉ាណែត[17] ដែលលោកទទួលបានគាំទ្រជាសាធារណៈជាមេដឹកនាំបន្ទាប់របស់កម្ពុជាក្នុងខែធ្នូ ឆ្នាំ២០២១[18] គណបក្សប្រជាជនកម្ពុជាបានធ្វើតាមភ្លាមៗ និងបានអនុម័តជាផ្លូវការចំពោះលោក ហ៊ុន ម៉ាណែត ជាបេក្ខភាពអនាគតនាយករដ្ឋមន្ត្រីបន្ទាប់ពីឪពុកលោកចូលនិវត្តន៍។[19]

ចំពោះការដាក់ចេញនូវនីតិវិធីលាលែងពីតំណែងនាយករដ្ឋមន្ត្រីនេះ ត្រូវបានគេមើលឃើញថា ជាការបង្ហាញពីផែនការរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាន់អំណាចអស់រយៈពេល ៣៧ឆ្នាំ ក្នុងការលាលែងពីតំណែង ដើម្បីអនុញ្ញាតឱ្យកូនប្រុសរបស់លោកបន្តតំណែងជាប្រមុខរដ្ឋាភិបាលនាពេលខាងមុខ។

លើសពីក្តីកង្វល់ផ្នែកនយោបាយទាំងនេះ ការកែប្រែរដ្ឋធម្មនុញ្ញដែលបានអនុម័តនៅកាលពីខែសីហា ឆ្នាំ២០២២ ដែលជាវិសោធនកម្មលើកទី ១០ នៃរដ្ឋធម្មនុញ្ញកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ មក ហើយបន្ទាប់ពីការប្រកាសឱ្យប្រើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ៩ កាលខែវិច្ឆិកា ឆ្នាំ ២០២២។ រាជរដ្ឋាភិបាលបានអនុម័តលើការកែសម្រួលរដ្ឋធម្មនុញ្ញទាំងនេះ ដោយមិនមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងសាធារណៈជន

---

[16] លោក ឃុន ណារីម «ក្រសួងយុត្តិធម៌ទម្លាក់សំណើការកែប្រែរដ្ឋធម្មនុញ្ញ» (CamboJA, ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២)។

[17] RFA, "ផែនការផ្ទេរអំណាចពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅឱ្យកូនប្រុសជាមុន" (RFA, ១៤ កក្កដា២០២២)។

[18] លោក សោម សារ៉ាត់ «លោក ហ៊ុន សែន គាំទ្រកូនប្រុសច្បងធ្វើជាមេដឹកនាំប្រទេសបន្ទាប់» (CamboJA, ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០២១)។

[19] លោក វី សុចាន់ «CPP គាំទ្រអនាគតនាយករដ្ឋមន្ត្រីរបស់ ម៉ាណែត» (ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១)។

កម្ពុជា។ គួរកត់សំគាល់ថារដ្ឋាភិបាលតែងបញ្ជូនសេចក្តីព្រាងវិសោធនកម្មរដ្ឋធម្មនុញ្ញនេះយ៉ាងឆាប់រហ័សដោយគ្មានការពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយសង្គមស៊ីវិល និងសាធារណជន ដូចដែលវិសោធនកម្មរដ្ឋធម្មនុញ្ញមុនៗដែលនេះបានរំលងនៅគោលការណ៍ប្រជាធិបតេយ្យដែលគាំទ្រដោយរដ្ឋធម្មនុញ្ញ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។

## ៣.អនុសាសន៍ជូនរដ្ឋាភិបាល

ដូចបានពិពណ៌នាមកពីខាងលើ ម.ស.ម.ក សូមផ្តល់អនុសាសន៍ជូនរដ្ឋាភិបាលដូចខាងក្រោម៖

- គោរពរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃប្រទេស មានន័យថារដ្ឋាភិបាលត្រូវបញ្ឈប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដោយផ្អែកតាមការយល់ឃើញតក់ក្រហល់ ឬក្នុងបំណងសម្រេចនូវផលប្រយោជន៍នយោបាយ។ រដ្ឋធម្មនុញ្ញអាចធ្វើវិសោធនកម្មទៅបានលុះត្រាតែក្នុងករណីចាំបាច់ និងដើម្បីបម្រើដល់ប្រយោជន៍របស់ប្រជាពលរដ្ឋប៉ុណ្ណោះ។ ក្នុងន័យនេះ រដ្ឋាភិបាលត្រូវពិចារណាដោយល្អិតល្អន់ ព្រមទាំងឱ្យមានការចូលរួមពិភាក្សាទៅលើការកែប្រែណាមួយនៃរដ្ឋធម្មនុញ្ញជាមួយតួអង្គពាក់ព័ន្ធ ក្នុងនោះរួមទាំងតំណាងអង្គការសង្គមស៊ីវិល និងសាធារណជន ដើម្បីធានាថាសំឡេងរបស់ប្រជាពលរដ្ឋត្រូវបានដឹងឮពេញលេញ។ រដ្ឋាភិបាលគួរអនុវត្តនូវបទប្បញ្ញត្តិក្នុងជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ ដោយរៀបចំឱ្យមានអង្គសមាជថ្នាក់ជាតិប្រចាំឆ្នាំដែលអនុញ្ញា ឱ្យពលរដ្ឋអាចចូលរួមពិភាក្សាផ្ទាល់អំពីបញ្ហានានាទាក់ទងនឹងផលប្រយោជន៍ជាតិជាមួយថ្នាក់ដឹកនាំ ដែលរហូតមកដល់ពេលនេះពុំទាន់មានការរៀបចំកម្មវិធីបែបនេះនោះទេ។
- ការពារសិទ្ធិ គុណតម្លៃ និងគោលការណ៍នានាដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ក្នុងនោះរួមទាំងគោលការណ៍នៃការបែងចែកអំណាចដែលធានាដោយមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ ដោយធានានូវតុល្យភាពអំណាចរវាងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ដោយគ្មានស្ថាប័នណាមួយមានអំណាចជាងស្ថាប័នណាមួយនោះឡើយ។ ការគោរពនូវគោលការណ៍នេះពីសំណាក់ រដ្ឋាភិបាលមានសារៈសំខាន់ដើម្បីទប់ស្កាត់ការបំពានអំណាច និងធានានូវដំណើរការល្អនៃលទ្ធិប្រជាធិបតេយ្យដែលប្រជាពលរដ្ឋគឺជា «ម្ចាស់ប្រទេស» (មាត្រា៥១)។

**ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែម ឬក៏មានបំណងផ្តល់មតិយោបល់ណាមួយ សូមផ្ញើអ៊ីម៉ែលមកកាន់លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមរយៈ chaksopheap@cchrcambodia.org ឬទាក់ទងមកយើងតាមរយៈទូរស័ព្ទៈ (០) ២៣ ៧២ ៦៩ ០១ ឬអាសយដ្ឋាន ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។**